# ជំពូកទី ៩

## ៩. ការវាយតំលៃសេដ្ឋកិច្ច

### ៩.១ ការគណនា វារីថាមពលនិងសេដ្ឋកិច្ចថាមពល សំរាប់ជំរើសទីតាំងទំនប់

ផ្អែកតាមឯកសារធារទឹកមធ្យមប្រចាំខែចំពោះទីតាំងទំនប់ និង ខ្សែកោង Q=f(H) នៅខ្សែទឹកខាងក្រោមរបស់អាគារផលិតថាមពលនៃជំរើសទីតាំងទំនប់នីមួយៗ លទ្ធផលគណនាថាមពលពីជំរើសទីតាំងទំនប់មានដូចតទៅៈ

**តារាងទី ៦០កៈ** ប៉ារ៉ាម៉ែត្រសំខាន់ៗ

| ល.រ | ប៉ារ៉ាម៉ែត្រ | | ខ្នាត | តំលៃលេខ |
|---|---|---|---|---|
| ១ | ផ្ទៃរងទឹកភ្លៀង | Flv | $km^2$ | 49200 |
| ២ | ធារទឹកមធ្យមប្រចាំឆ្នាំ | Qo | $m^3/s$ | 1306 |
| ៣ | នីវ៉ូទឹកផ្គត់ផ្គង់ពេញលេញ | FSL | m | 75 |
| ៤ | នីវ៉ូទឹកប្រតិបត្តិការអប្បបរមា | MOL | m | 74 |
| ៥ | បរិមាណស្តុកទឹក | Wtb | $10^6m^3$ | 1792.5 |
| ៦ | ចំនុះអាងស្តុកទឹកដែលមិនអាចប្រើបាន | Wc | $10^6m^3$ | 1459.3 |
| ៧ | ចំនុះទឹកដែលប្រើការបាន | Whi | $10^6m^3$ | 333.2 |
| ៨ | ផ្ទៃអាងស្តុកទឹកទាក់ទិនទៅនឹង FSL | Fmh | $km^2$ | 334.4 |
| ៩ | ធារទឹកអតិបរមាឆ្លងកាត់អាគារផលិតថាមពល | Qmax | $m^3/s$ | 2037.5 |
| ១០ | កំពស់ទឹកអតិបរមា | Hmax | m | 28.5 |
| ១១ | កំពស់ទឹកអប្បបរមា | Hmin | m | 18.9 |
| ១២ | អត្រាកំពស់សំពាធទឹក | Htk | m | 21.8 |
| ១៣ | សមត្ថភាពតំឡើង | Installed cap. | MW | 400 |
| ១៤ | សមត្ថភាពនៃទួប៊ីនមួយគ្រឿង | Firm capacity | MW | 104 |
| ១៥ | ថាមពលមធ្យមប្រចាំឆ្នាំ | Eo | $10^6$k Wh | 1953.9 |
| ១៦ | ចំនួនម៉ោងប្រើក្នុងការផលិតថាមពល | hsd | Hour | 4885 |

Draft

**តារាងទី ៦០ខ:** លទ្ធផលចំណេញពីការប្រមាណរបស់គំរោង

| ប៉ារ៉ាម៉ែត្រ | ខ្នាត | ជំរើសទី ១ | ជំរើសទី ២.១ | ជំរើសទី ២.២ |
|---|---|---|---|---|
| **អាងស្តុកទឹក** | | | | |
| ទីតាំងទំនប់ | | ទីតាំងទី ១ | ទីតាំងទី ២.១ | ទីតាំងទី ២.២ |
| FSL | m | ៧៥ | ៧៥ | ៧៥ |
| MOL | m | ៧៤ | ៧៤ | ៧៤ |
| Wtb | $10^6m^3$ | ១៧៩២.៥ | ២២៩៦.៥ | ២២៩៦.៥ |
| Wc | $10^6m^3$ | ១៤៥៩.៣ | ១៩១៧.១ | ១៩១៧.១ |
| Whi | $10^6m^3$ | ៣៣៣.២ | ៣៧៩.៤ | ៣៧៩.៤ |
| **អាគារផលិតថាមពល** | | | | |
| ទីតាំងអាគារផលិតថាមពល | | នៅនឹងទំនប់ | នៅនឹងទំនប់ | នៅនឹងទំនប់ |
| Qmax | $m^3/s$ | ២០៣៧.៥ | ២០៥៤.៦ | ២០៥៨.៥ |
| Hmax | m | ២៨.៥ | ២៩.២ | ៣១.៣ |
| Hmin | m | ១៨.៩ | ២០.០ | ២៤.៣ |
| Htk | m | ២១.៨ | ២២.៧ | ២៦.២ |
| សមត្ថភាពតំឡើង | MW | ៤០០.០ | ៤២០.០ | ៤៨០.០ |
| សមត្ថភាពនៃទួប៊ីនមួយគ្រឿង | MW | ១០៤.០ | ១០៩.០ | ៩៧.៥[8] |
| Eo | $10^6$kWh | ១៩៥៣.៩ | ២០៣០.៩ | ២២៣៥.០[8] |
| ចំនួនម៉ោងប្រើក្នុងការផលិតថាមពល | hour | ៤៨៨៥ | ៤៨៣៥ | ៤៦៥៦ |
| ចំនួនគ្រួសារតាំងលំនៅសារជាថ្មី | គ្រួសារ | ១៥៧៩ | ១៥៩០ | ១៥៩០ |
| ចំនួនប្រជាជនត្រូវតាំងលំនៅសារថ្មី | នាក់ | ៦៥០៧ | ៦៥៤០ | ៦៥៤០ |
| តំលៃទុនវិនិយោគ | $១០^6$ ដុល្លា | ៦៦៧ | ៧១០ | ៨១៥ |
| **សូចនាករហិរញ្ញវត្ថុ** | កម្ចីបរទេស: ៦%/ឆ្នាំ , កម្ចីក្នុងស្រុក: ១៣%/ឆ្នាំ | | | |
| **តំលៃថាមពល** | USc/kWk | **៦.៣០** | **៦.៤១** | **៦.៥៩** |
| FNPV | លានដុល្លា | ៦៩.៣៤ | ៦៩.៣៤ | ៦៩.៣៤ |
| FIRR | % | ១២.៤២ | ១២.២៧ | ១១.៩៨ |
| B/C | - | ១.១២ | ១.១២ | ១.១០ |

* ថាមពលដោយមិនគិតពីការបង្ហូរទៅលើបរិស្ថាន= *100m3/s*

Draft

## ៩.២ ការជ្រើសរើសទីតាំងទំនប់

បន្ទាប់ពីការគិតគូរពីជំរើសទីតាំងទំនប់ វាអាចមានដូចខាងក្រោមនេះ :

ក្នុងន័យប្រសិទ្ធិភាពសេដ្ឋកិច្ចៈ ការគណនាលទ្ធផលនៃសុចនាករហិរញ្ញវត្ថុផ្នែកតាមគោលគំនិតរក្សា NPV មិនប្រែប្រួលសំរាប់ជំរើសទាំងអស់។ ទីតាំងទំនប់ជំរើសទី១ បង្ហាញថាមានលក្ខណៈប្រសើរបំផុតសំរាប់ផ្នែកហិរញ្ញវត្ថុ ដែល FIRR (១២.៤២%) មានខ្ពស់ជាងប្រៀបធៀបទៅនឹងជំរើស ២.១ (១២.២៧%) និង ២.២ (១១.៩៨%)។ ម្យ៉ាងវិញទៀត ការពិចារណាពីសុចនាករនៃ B/C ក៏ខ្ពស់ដែរ ។ ក្នុងករណីជំរើសទី២ នោះទុនវិនិយោគនឹងកើនបន្ថែម ប្រហែល ២៤០០ ពាន់លានដុង (១៤៣.៧ លានដុល្លាអាមេរិក) បើប្រៀបធៀបទៅនឹងជំរើសទី១ ប៉ុន្តែថាមពល ផលិតកើនបានតែ ២៨១.៥លាន KWh ប៉ុណ្ណោះ ។ វាមានន័យថាតំលៃវិនិយោគបន្ថែមនេះ មិនមានប្រសិទ្ធិភាព សេដ្ឋកិច្ចនោះទេ ដោយធៀបនឹងជំរើសទី១។

ក្នុងន័យលក្ខណៈភូគព្ភសាស្ត្រវិស្វកម្មៈ នៅបាតទន្លេ ជំរើសទីតាំងទំនប់ទី១ មានលក្ខណៈភូគព្ភសាស្ត្រប្រសើរ ជាង ប៉ុន្តែលក្ខណៈភូគព្ភសាស្ត្ររបស់ជំរើសទី២ ក៏ត្រូវទៅតាមតំរូវការសំរាប់ទ្រទ្រង់សំណង់បង្ហៀរធ្វើពីបេតុង។ បាយអទ្រនាប់បាតគ្រឹះត្រូវការចាំបាច់សំរាប់ជំរើសទាំងពីរ។ ផ្នែកទំរក្បាលទំនប់ទាំងសងខាងនៃទំនប់ចាក់ដីបង្ហាប់ស្មើ សាច់ ដើម្បីអោយក្បាលទំនប់ផ្នែកទាំងពីរមានលក្ខណៈដូចគ្នា។

តាមលក្ខណៈសំណង់ ជំរើសទីតាំងទំនប់ T2.2 មានលក្ខណៈសមស្របពីព្រោះផ្លូវទឹក ត្រូវបានសាងសង់ដោយ ឯករាជ្យនៅលើច្រាំងខាងស្តាំ ប៉ុន្តែលក្ខណៈភូគព្ភសាស្ត្រមិនល្អដូចទៅនឹងលក្ខណៈភូគព្ភសាស្ត្រក្នុងជំរើសទីតាំង T1 ទេ ប៉ុន្តែតំរូវអោយមានសំណង់បង្ហៀរតែនៅរដូវទឹកជំនន់ប៉ុណ្ណោះ ដូចនេះតំលៃសំរាប់សំណង់បង្ហៀរត្រូវបានកាត់បន្ថយ។ ក្រៅពីនេះការរៀបចំសំណង់កាន់តែមានអត្ថប្រយោជន៍ថែមទៀត ដោយសារគ្រោងរបស់សំណង់តាមមុខនិមួយៗ ដាច់ៗពីគ្នា មិនផ្តោតទៅលើតំបន់ដូចគ្នាទៅនឹងទីតាំង T1 ទេ។ នីវ៉ូផ្នែកតាមធម្មជាតិក៏មានកំរិតទាបជាងផងដែរ ដូចនេះភាពអាចទុកចិត្តបាននៅលើកាលវិភាគក៏ខ្ពស់តាមនោះផងដែរ។

ក្នុងន័យដំណើរការនៅពេលអនាគតៈ ជំរើសទីតាំងទំនប់ T1 និង T2.1 មានគុណវិបត្តិនៅលើប្រតិបត្តិការ របស់សំណង់បង្ហៀរ។ វាអាចមានឥទ្ធិពលដោយផ្ទាល់ទៅលើដំណើរការអាគារផលិតថាមពល ដោយរចនាសម្ព័ន្ធទាំង នេះត្រូវបានរៀបចំជិតគ្នា។ ដើម្បីបំបាត់ឥទ្ធិពលនេះ ជញ្ជាំងបាំងចាំបាច់ត្រូវមានដើម្បីរៀបចំបែងចែកតំបន់នេះជាពីរ ដូចនេះការរំខានដល់នីវ៉ូទឹកនៅខ្សែទឹកខាងក្រោមត្រង់សំណង់បង្ហៀរ នឹងមិនមានផលប៉ះពាល់ដល់តំបន់ខ្សែទឹកខាង ក្រោមរបស់អាគារផលិតថាមពលទេ។

តាមការវិភាគ និង គណនាដូចរៀបរាប់ពីខាងលើ ជំរើសទីតាំងទំនប់ T2.2 ត្រូវបានស្នើឡើងជាជំរើសសំណើ សុំដើម្បីអនុវត្តការសិក្សាជាបន្តបន្ទាប់។

Draft

ការជ្រើសរើសទីតាំងទំនប់ព្រមទាំងប៉ារ៉ាម៉ែត្រផ្សេងៗរបស់គំរោង គឺពឹងផ្អែកទៅលើសុចនាករសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ជំរើស ប៉ុន្តែទិន្នន័យដែលដាក់បញ្ចូលបំរើអោយការគណនានេះកំពុងធ្វើការគិតស្មានពីភ្នាក់ងារពិគ្រោះយោបល់តាមកំរិតធម្មតានៅប្រទេសវៀតណាម សព្វថ្ងៃនេះ ហើយទំរង់នៃការវិនិយោគក៏ត្រូវបានគិតស្មានដើម្បីធ្វើ BOT ផងដែរក្នុងកំឡុងពេល ៣០ ឆ្នាំ ។ ហេតុនេះនៅជំហានបន្ទាប់ (ការសិក្សាពីសមិទ្ធិលទ្ធភាព) នៅពេលដែលអ្នកវិនិយោគមានព័ត៌មានកាន់តែត្រឹមត្រូវពីដើមទុនបែបបទវិនិយោគ... ប៉ារ៉ាម៉ែត្ររបស់គំរោង (ដោយរាប់បញ្ចូលទាំងទីតាំងទំនប់) នឹងត្រូវបានគណនា និង កែតំរូវ ។

ជំរើសទីតាំងទំនប់ទាំងពីរ ត្រូវបានពិចារណាសំរាប់ទំនប់ៈ ទីតាំងទី១ គឺនៅចំងាយ ១,៥ គ.ម នៅខ្សែទឹកខាងក្រោមនៃចំនុចប្រសព្វរវាងទន្លេស្រែពកនិងសេសាន ហើយទីតាំងទី២ គឺនៅចំងាយ ៥ គ.ម ពីខ្សែទឹកខាងក្រោមនៃចំនុចប្រសព្វរវាងទន្លេស្រែពកនិងសេសាន។ បន្ទាប់ពីការពិចារណានៃភូគព្ភសាស្ត្រ និង បញ្ហាសង្គមរបស់ទីតាំងទី ១ ត្រូវបានជ្រើសរើសជាទីតាំងអាទិភាពជាងគេ។ ភូគព្ភសាស្ត្រមានភាពប្រសើរជាងទីតាំងទី ២ សំរាប់គ្រឹះទំនប់, មានការកាត់បន្ថយផ្ទៃអាងប្រហែល ៤៥០០ ហិកតា (ពី ៣៨,០០០ ទៅ ៣៣,៥០០ ហិកតា) និងមិនតំរូវអោយមានការប្តូរទីតាំងនៃភូមិភ្លុកចំនួនច្រើន។ បន្ថែមទៅទៀតវាន័យថា កន្លែងខ្លះមានទឹកធ្លាក់ ហើយក្រោមទីតាំងទី ១ មិនត្រូវបានលិចលង់ទាំងស្រុងនោះទេ។

## ៩.៣ ការជ្រើសរើសកំរិតផ្គត់ផ្គង់ពេញលេញ

### ៩.៣.១ ដែនកំណត់លើរយៈកំពស់នៃការរៀបចំប្លង់នីវ៉ូទឹក

ជំរើសមួយចំនួនសំរាប់កំពស់ទំនប់ត្រូវបានពិចារណាចន្លោះពី ៨០ម ទៅ ៧០ម ធៀបនឹងនីវ៉ូសមុទ្រ។ ជាមួយកំរិតផ្គត់ផ្គង់ពេញលេញ (FSL) ៧៥ម ធៀបនឹងនីវ៉ូសមុទ្រ គឺជាកំពស់ដែលប្រសើរជាង ដើម្បីបង្រួមឱ្យតូចបំផុតនៃផ្ទៃអាង ខណៈដែលរក្សាហិរញ្ញវត្ថុនៃគំរោងអាចសំរេចទៅបាន។

ជាគោលការណ៍ ប៉ារ៉ាម៉ែត្រពីការរៀបចំនីវ៉ូទឹក កំរិតផ្គត់ផ្គង់ពេញលេញ (FSL) និង កំរិតផ្គត់ផ្គង់អតិប្បរមា (MOL) ត្រូវបានជ្រើសរើសដោយផ្អែកតាមការប្រៀបធៀបបច្ចេកទេស-សេដ្ឋកិច្ច សំរាប់ការដាក់បញ្ចូលនៃជំរើសនានានៃការរចនារៀបចំនីវ៉ូទឹក ដោយគិតគូរពីបទដ្ឋាននៃដីល្បាប់នៅក្នុងអាងស្តុក។ សំរាប់បាតអាងស្តុកនៃរោងចក្រវារីអគ្គិសនីសេសានក្រោម២ ដែនកំណត់ខាងលើនៃ FSL មិនទាន់ប្រាកដទេ FSL ដែលជ្រើសរើសគឺជា នីវ៉ូទឹកជាមួយនឹងសុចនាករសេដ្ឋកិច្ចនិងហិរញ្ញវត្ថុល្អបំផុត ពីមូលដ្ឋាននៃការវិភាគពីប្រាក់ចំណេញដែលទាញយកបានពីថាមពល និង តំលៃសំណងសំរាប់ការខូចខាត- ការផ្លាស់ប្តូរទីលំនៅសារជាថ្មី បណ្តាលពីការលិចលង់ក្នុងអាង។

ការគិតពី MOL ទាបបំផុតត្រូវបានកំនត់ផ្អែកទៅតាមបទដ្ឋានរបស់អាងស្តុកទឹក។ ដោយផ្អែកតាមបទដ្ឋានសំណង់របស់វៀតណាម TCXD VN-285-2002 មាឌល្បាប់របស់អាងស្តុកហាក់ដូចជាត្រូវបានចាក់បំពេញនៅពេល

Draft

កើនឡើងកំពស់របស់កំទេចកំណផ្ទៃលើនៅខាងមុខតំបន់រងសំពាធឡើងដល់កំរិតកំពស់របស់ច្រកចូលចម្បង (main intake)។ ដោយផ្អែកតាមបទបញ្ជានៅក្នុង TCXD VN-285-2002 សំរាប់រោងចក្រវារីអគ្គីសនីសេសានក្រោម ២ រយៈពេលប្រមូលផ្តុំកករសំរាប់បំពេញអោយពេញ គឺមិនតិចជាងរយៈពេល១០០ឆ្នាំទេ ។ ការសិក្សាពីភូគព្ភសាស្ត្រ នៅអាងស្តុកទឹកបង្ហាញថា ការរអិលដីបាក់នៅក្នុងអាងស្តុកមិនអាចនឹងកើតឡើងបានទេ មានតែការរអិលដីបាក់តិចតួចប៉ុណ្ណោះអាចកើតឡើងបាន។ ហេតុដូចនេះ មាឌកករនៅក្នុងអាងស្តុកទឹកភាគច្រើនជាល្បាប់ភក់ដែលអណ្តែតនៅក្នុងរំហូរទឹក។ អាងស្តុកនៃគំរោងសេសានក្រោមទី២ ត្រូវបង្កើតជាផ្ទៃអាងធំមួយលើដៃទន្លេសំខាន់ៗទាំងពីរ (សេសាន និងស្រែពក) ដែលមានចំណោតបាតតូច ល្បឿនរំហូរនឹងត្រូវថយចុះនៅពេលរំហូរហូរចូលទៅក្នុងពោះអាងរីកធំនៅខ្សែទឹកខាងក្រោម ដូចនេះភាគច្រើននៃដីល្បាប់នឹងរងកករជាប់នៅតំបន់នេះ។ ការគណនាពីកំណកល្បាប់នៅក្នុងអាងបង្ហាញថា បន្ទាប់ពីរយៈពេល ១០០ឆ្នាំ កំពស់កំទេចកំណកភក់ល្បាប់ឡើងដល់រយៈកំពស់ ៥៣ម (ធៀបនឹងនីវ៉ូសមុទ្រ)។ ដោយយោងទៅតាមលក្ខណៈនេះ ស្រទាប់ដីកំណកនៅច្រកចូលនឹងមានមិនតិចជាងរយៈកំពស់ ៥៥ម នោះទេ។ ជាមួយនឹងធារទឹកដែលបានកំនត់សំរាប់រោងចក្រវារីអគ្គិសនីបង្កើតសមត្ថភាពផលិតថាមពលខុសគ្នានោះ ការពន្លិចមាត់ទ្វារច្រកចូលទឹកត្រូវស្ថិតនៅក្រោមនីវ៉ូប្រតិបត្តិការអប្បបរិមា (MOL) ប្រហែល ១៥ម។ ធ្វើដូចនេះដើម្បីធានាបាននូវតំរូវការអាងសំរាប់កំទេចកំណដោយផ្អែកលើ TCXD VN-285-2002 ដែលមានរយៈកំពស់ MOL ទាបបំផុតនៃរោងចក្រវារីអគ្គិសនីសេសានក្រោមទី២ គឺមិនស្ថិតនៅក្រោមរយៈកំពស់ ៧១ម ទេ នៅពេលដែលគិតគូរ និង ជ្រើសរើសប៉ារ៉ាម៉ែត្រដែលសំរាប់កំណត់អាងស្តុក។

Draft

ពីការវិភាគខាងលើ ដែនកំណត់នៅក្នុងការគណនានីវ៉ូទឹកដែលបានកំណត់របស់រោងចក្រវារីអគ្គិសនីសេសានក្រោមទី ២ ត្រូវបានកំណត់ដូចខាងក្រោមៈ

- នីវ៉ូទឹកផ្គត់ផ្គង់ពេញលេញៈ ដោយផ្អែកតាមការគណនាប្រសើរបំផុតរបស់នីវ៉ូទឹក
-នីវ៉ូប្រតិបត្តិអប្បបរិមាៈ មិនស្ថិតនៅក្រោមរយៈកំពស់ ៧១ ម។

## ៩.៣.២ ប៉ារ៉ាម៉ែត្រមូលដ្ឋានក្នុងការគណនា និង ការជ្រើសរើស FSL

រំហូរប្រចាំឆ្នាំជាប់ៗគ្នាៈ តាមការគណនា និង ការជ្រើសរើស កំណត់ប្លង់នីវ៉ូទឹក នោះរំហូរហៀរចេញ (runoff) ប្រចាំឆ្នាំជាប់ៗគ្នា ដែលបានប្រើប្រាស់នៅក្នុងការគណនា គឺជារំហូរហៀរចេញជាប់ៗគ្នាចាប់ពីឆ្នាំ ១៩៧៧ ដល់ ២០០៦ ដែលមានរំហូរហៀរចេញមធ្យមប្រចាំឆ្នាំគឺ $Q_o = 1304\ m^3/s$។ ការកំណត់ជាមូលដ្ឋានសំរាប់រំហូរហៀរចេញប្រចាំឆ្នាំ មានរៀបរាប់នៅក្នុងការសិក្សាពីឧតុនិយម-ជលសាស្ត្រក្នុងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោង។

មាឌស្តុករបស់អាងៈ នៅក្នុងការរៀបចំរបាយការណ៍សិក្សាពីបុរេសមិទ្ធិលទ្ធភាព ផែនទីដែលថតរូបពីលើអាកាស មាត្រដ្ឋាន ១:១០000 នៃផ្ទៃអាងស្តុកទឹកទាំងមូលត្រូវបានវាស់វែងជាមួយនឹងខ្សែកំពស់គំលាត២ម ចាប់ពី

អាងស្តុកទឹកនោះ មាឌត្រូវបានវាស់ និង កំណត់ជាមួយរយៈកំពស់ខុសគ្នា ហើយទំនាក់ទំនងខ្សែកោងរវាងមាឌ និង រយៈកំពស់ (W,F = f (z)) ត្រូវបានបង្កើតឡើង ។

ការគណនាការបំពេញទឹកត្រលប់ (Back water) នៃអាងស្តុកៈ ដោយផ្អែកលើប្រព័ន្ធឯកសារពំនុះកាត់របស់ទន្លេដែលរៀបចំដោយ PECC1 និង PECC4 កំឡុងពេលគណនាពីអ៊ុដ្រូឌីណាមិចនៅខ្សែទឹកក្រោមរបស់ទន្លេសេសាន និងទន្លេស្រែពកក្នុងដែនដីកម្ពុជានៅឆ្នាំ ២០០៤ រួមជាមួយផែនទីដែលថតរូបពីលើអាកាសខ្នាត ១:១០000 សំរាប់ផ្ទៃអាងស្តុកទឹកទាំងមូល, ដោយផ្អែកតាមឯកសារអង្កេតតាមដានប្រចាំឆ្នាំ និងតាមប្រវត្តិទឹកជំនន់ ព្រមទាំងតាមឋានលេខារបស់ដៃទន្លេទាំងពីរ ភាពមូលនៃផ្ទៃអាងស្តុកត្រូវបានធ្វើតាមម៉ូដែលដើម្បីគណនាការបំពេញទឹកត្រលប់ដែលទាក់ទងទៅនឹងប្រេក្វង់របស់ជំនន់ ៥% ដោយគិតរួមជាមួយអាងស្តុកដែលរងកករល្បាប់បន្ទាប់ពីរយៈពេល ៥០ ឆ្នាំ ។ ការគណនាល្បាប់ក្នុងអាងលំអិត សូមមើលនៅសេចក្តីបន្ថែម, លទ្ធផលជាមួយ FSL ៧៥ម នៅដៃទន្លេសេសានជាមួយនឹងទឹកបំពេញត្រលប់នៅខ្សែទឹកលើនៅទីតាំងដែលជាចំនុចបញ្ចប់ (៣៩គ.ម ពីទីតាំងទំនប់ទី ២) គឺ +១,២ម ។ ចំពោះដៃទន្លេស្រែពក ដែលមានចំណោតទន្លេទាប១ នោះចន្លោះចំងាយនៃឥទ្ធិពលពីការបំពេញទឹកត្រលប់ មានប្រវែងវែងជាង (៦០គ.ម ពីទីតាំងទំនប់ទី ២) គឺ +២,៣ម ។

ការខូចខាតនៃអាងទាក់ទងទៅនឹងនីវ៉ូទឹកៈ ក្នុងពេលអនុវត្តនិងសិក្សា ខ្សែព្រំប្រទល់របស់បាតអាង ត្រូវបានបង្កើតឡើងដោយមានទំនាក់ទំនងទៅនឹងភាពខុសគ្នារបស់រយៈកំពស់ (ខុសគ្នា ១ម) ។ ដោយផ្អែកតាមប្រព័ន្ធកំណត់សញ្ញានេះ ក្រុមអង្កេតពីការខូចខាតនឹងចុះបញ្ជីចំនួនគ្រួសារ ចំនួនលំនៅដ្ឋាន ការខូចខាតលើដីលំនៅដ្ឋាន ដីចំការ ដីកសិកម្មពនេរចរ ដីព្រៃ ប្រភេទដើមឈើ ឈើហូបផ្លែ ដែលទាក់ទងទៅនឹងនីវ៉ូទឹកនីមួយ១ចាប់ពីការខូចខាតនោះ តំលៃសំរាប់សំណង និងការផ្លាស់ប្តូរទីលំនៅត្រូវបានគណនាសំរាប់ជំរើស FSL នីមួយ១ ដោយគិតទៅតាមការបំពេញទឹកត្រលប់ ។

### ៥.៣.៣ បរិមាណការងារសំខាន់១សំរាប់ជំរើស FSL

ដោយផ្អែកតាមជំរើសដែលបានរៀបចំនៅក្នុងការជ្រើសរើសប្លង់នីវ៉ូទឹកដូចរៀបរាប់នៅក្នុងផ្នែក "V.២.៣" និង ចន្លោះប្លង់នីវ៉ូទឹកដែលបានសិក្សាដូចមានក្នុងផ្នែក "V.២.១" ការគណនាសំរាប់បរិមាណជំរើសរបស់ FSL ត្រូវបានធ្វើឡើង ។

**តារាងទី ៦១:** បរិមាណនៃជំរើស FSL

| ការងារ | ខ្នាត | FSL=៧៤ | FSL=៧៥ | FSL=៧៦ |
|---|---|---|---|---|
| ការជីកដី | m3 | ១៤.១៧៩.៣២៧ | ១៤.២៤៩.២៥០ | ១៤.៣២១.០៧៩ |
| ទំនប់សណ្តការពារទឹក | m3 | ៨.៩២១.២៩៥ | ៩.៦២៩.០៧០ | ១០.៩១០.២២០ |
| បេតុង | m3 | ៦៤៤.៤១៤ | ៦៤៥.៦៩៦ | ៦៤៧.០១៣ |

Draft

| | | | | |
|---|---|---|---|---|
| សំភារៈ Hydro-mechanical | Ton | ៨.៧៨១ | ៨.៨០៨ | ៨.៨៣៦ |
| សំភារៈ Hydraulic-mechanical | MW | ៤៦០ | ៤៨០ | ៥០០ |

**តារាងទី ៦២:** តំលៃនៃជំរើស FSL

| ប៉ារ៉ាម៉ែត្រ | ខ្នាត | ជំរើស ១ | ជំរើស ២.១ | ជំរើស ២.២ |
|---|---|---|---|---|
| ទុនវិនិយោគសរុប | MUSD | ៥៩២.៧៥ | ៦១៨.១៨ | ៦៦៥.៣៨ |

### ៩.៣.៤ បរិមាណការងារសំខាន់ៗ និង តំលៃជំរើស MOL

ដោយផ្អែកតាមជំរើសនៃការរៀបចំដូចរៀបរាប់ខាងលើ បរិមាណសំណង់ និង តំលៃវិនិយោគសំរាប់ជំរើស MOL ត្រូវបានគណនា។

**តារាងទី ៦៣:** តំលៃនៃជំរើស MOL

| ប៉ារ៉ាម៉ែត្រ | ខ្នាត | ជំរើស | | | |
|---|---|---|---|---|---|
| FSL | m | ៧៥ | ៧៥ | ៧៥ | ៧៥ |
| MOL | m | ៧៤ | ៧៣ | ៧២ | ៧១ |
| ទុនវិនិយោគសរុប | MUSD | ៦១៨.១៥ | ៦១៩.៣៦ | ៦២០.៣១ | ៦២១.០៦ |

## *៩.៤ ធនធានធម្មជាតិនៅក្នុងគុណតំលៃសង្គម*

### ៩.៤.១ ជីវភាពសរុបប្រចាំឆ្នាំទទួលបានពីត្រីធម្មជាតិ

ជីវភាពសរុបប្រចាំឆ្នាំទទួលបានពីត្រីធម្មជាតិ ជាពិសេសសំរាប់ប្រជាជនដែលរស់នៅតាមដងទន្លេនៃខ្សែទឹកខាងលើរបស់ទីតាំងទំនប់ នឹងត្រូវបានគណនាដោយផ្អែកលើចំនួនមនុស្សសរុប និងតំលៃរបស់ត្រីនៅទីផ្សារក្នុងមូលដ្ឋាន។ តាមទស្សនៈ បរិស្ថានគេអាចទស្សន៍ទាយថាប្រជាជនដែលរស់នៅខ្សែទឹកខាងក្រោមរបស់ទីតាំងទំនប់ អាចបន្តសកម្មភាពនេសាទរបស់ពួកគេ ទោះបីជាទទួលផលប៉ះពាល់មួយចំនួនចំពោះផលិតកម្មត្រីក៏ដោយ (កើន ឬ ថយ) នៅក្នុងរយៈពេលគំរោងសាងសង់ និងប្រតិបត្តិ។

ត្រីចាប់សរុបនៅទន្លេសេសាន និង ទន្លេស្រែពកក្នុងខេត្តរតនៈគីរីត្រូវបានគណនាដោយផ្អែកតាម CPUE និងចំនួនម៉ោងដែលចាប់ក្នុងរយៈពេលមួយឆ្នាំ ជាលទ្ធផលក្រុមសិក្សា KCC អំពីត្រីនៅរដូវប្រាំងកំឡុងពេលចាប់ពីខែកុម្ភៈ-ឧសភា ២០០៨ និង ចំនួនប្រជាជនសរុបរស់នៅតាមដងទន្លេទាំងពីរក្នុងឆ្នាំ ២០០៧។



Draft

គុណតំលៃជីវភាពប្រចាំឆ្នាំដែលពឹងផ្អែកលើធនធានត្រីធម្មជាតិក្នុងតំបន់គំរោង

| ល.រ | ទីតាំងនៅក្នុងតំបន់គំរោង | ទិន្នផលក្នុងមួយឆ្នាំ (ត) | តំលៃទីផ្សារត្រីក្នុងតំបន់ (USD/kg) | តំលៃក្នុងមួយឆ្នាំ (USD) | តំលៃត្រីប្រចាំឆ្នាំសំរាប់គ្រួសារនិមួយៗ (USD) |
|---|---|---|---|---|---|
| ១ | ចាប់នៅទន្លេសេសាន ខ្សែទឹកខាងលើ ទីតាំងទំនប់ | ១១៨,០៤ | ២,៥ | ២៩៥.១០០,០០ | ១៥៧,៨៩ |
| ២ | ចាប់នៅទន្លេសេសាន ខ្សែទឹកខាងក្រោម ទីតាំងទំនប់ | ៤៥,២៧ | ២,៥ | ១១៣.១៧៥,០០ | ២២៥,០០ |
| ៣ | នៅទន្លេស្រែពក | ៥៥,០៧ | ២,៥ | ១៣៧.៦៧៥,០០ | ១៨៧,០៦ |
| | **សរុប** | **២១៨,៣៨** | | **៥៤៥.៩៥០,០០** | ១៧៥,៦៦ |

**<u>ចំណាំ:</u>** តំលៃត្រីក្នុងទីផ្សារខេត្តស្ទឹងត្រែងជាមធ្យម ២,៥ USD /គ.ក (មករា-ឧសភា ២០០៨)

គុណតំលៃជីវភាពប្រចាំឆ្នាំដែលពឹងផ្អែកលើធនធានត្រីធម្មជាតិ តំបន់លើគំរោង (នៅក្នុងខេត្តរតនៈគីរី)

| ល.រ | ទីតាំងនៅក្នុងតំបន់គំរោង | ទិន្នផលក្នុងមួយឆ្នាំ (ត) | តំលៃទីផ្សារត្រីក្នុងតំបន់ (USD/kg) | តំលៃក្នុងមួយឆ្នាំ (USD) | តំលៃប្រចាំឆ្នាំសំរាប់១គ្រួសារ (USD) |
|---|---|---|---|---|---|
| ១ | នៅទន្លេសេសាន ខេត្តរតនៈគីរី ដល់ព្រំប្រទល់វៀតណាម | ៤៧៣ | ៣ | ១.៤១៩.០០០,០០ | ៣៨៧,២៨ |
| ២ | នៅទន្លេស្រែពក ខេត្តរតនៈគីរី រហូតដល់ព្រំប្រទល់វៀតណាម | ១៧៧ | ៣ | ៥៣១.០០០,០០ | ៣៩០,១៥ |
| | សរុបៈ | | | **១.៩៥០.០០០,០០** | **៣៨៨,០៦** |

Draft

**<u>ចំណាំ:</u>** * យោងតាមលទ្ធផលសិក្សារបស់ មៀច និង Baird ឆ្នាំ២០០៥

- តំលៃត្រីក្នុងទីផ្សារខេត្តរតនៈគីរីជាមធ្យម ៣ USD /គ.ក (មករា-ឧសភា ២០០៨)
- អត្រាប្តូរប្រាក់ ១ USD = ៤០០០រៀល (មេសា ២០០៨)

រំពឹងថាគំរោងនឹងធ្វើឱ្យផលត្រីចាប់ថយចុះ ៥០% ដូចនេះ តំលៃផលត្រីប្រចាំឆ្នាំគឺ (**៥៤៥.៩៥០,០០** + **១.៩៥០.០០០,០០**) / ២ = **១.២៤៧.៩៧៥,០០ ដុល្លាអាមេរិក**

### ៩.៤.២ ជីវភាពសរុបប្រចាំឆ្នាំទទួលបានពីផលិតផលព្រៃឈើ

យោងទៅតាមគ្រួសារដែលបានសម្ភាសន៍ ៥០២ គ្រួសារនៅក្នុងការសិក្សាស្រាវជ្រាវពី " ផលប្រយោជន៍ពីព្រៃឈើធម្មជាតិ និង ការវិភាគសេដ្ឋកិច្ចនៃការអភិរក្សព្រៃឈើធម្មជាតិនៅក្នុងប្រទេសកម្ពុជា = Natural Forest Benefit and Economic Analysis of Natural Forest Conservation in Cambodia" បោះពុម្ពផ្សាយដោយ

CDRI ខែធ្នូ ២០០៦ បញ្ជាក់ថាគុណតំលៃជីវភាពនៃតំលៃប្រើប្រាស់ក្នុងតំបន់ និងការលក់ផលិតផលព្រៃឈើ អនុផលព្រៃ ដែលទទួលបានពីព្រៃធម្មជាតិនៅក្នុងខេត្តចំនួន ៤ របស់ប្រទេសកម្ពុជា (កំពង់ធំ ក្រចេះ មណ្ឌលគិរី និង ពោធិ៍សាត់) នៅក្នុងកំឡុងពេលមួយឆ្នាំ មានភាពខុសគ្នាពីខេត្តមួយទៅខេត្តមួយ សូមមើលលលទ្ធផលនៃគុណតំលៃ ដូចខាងក្រោម:

- ក្នុងខេត្តកំពង់ធំ ២៦៥USD/ គ្រួសារ
- ក្នុងខេត្តក្រចេះ ៤២៤ USD/ គ្រួសារ
- ក្នុងខេត្តមណ្ឌលគិរី ១៦៧ USD/ គ្រួសារ
- ក្នុងខេត្តពោធិ៍សាត់ ៣១៤ USD/ គ្រួសារ

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដោយផ្អែកតាមលទ្ធផលស្ទង់មតិពីសេដ្ឋកិច្ចសង្គមនៅក្នុងឃុំចំនួនបួនរបស់តំបន់គំរោង (ខេត្តស្ទឹងត្រែង) ជាមួយនឹងគ្រួសារចំនួន ១៩១ ដែលបានសម្ភាសន៍ ដោយក្រុមសិក្សា EIA របស់ KCC ពីខែ កុម្ភៈ-មេសា ២០០៨ បានរកឃើញថា ១៣.៦% ក្នុងចំណោម ១៩១ គ្រួសារ មានប្រាក់ចំណូលចម្បងបានពីអនុផលព្រៃ ហើយប្រាក់ចំណូលប្រចាំខែរបស់គេគឺ ៧២USD/គ្រួសារ ឬ ៨៦៤ USD/គ្រួសារ/ឆ្នាំ។ តំលៃនេះមិនអាចអនុវត្តបានពេញក្នុងសហគមន៍ទេ តែវាជាមូលដ្ឋានគ្រឹះសំរាប់ការសិក្សាពីចំណូលរបស់ប្រជាជនក្នុងតំបន់គំរោង។

សន្ទត់ជីវភាពសរុបប្រចាំឆ្នាំនៃគ្រួសារនិមួយៗ ដែលទទួលបានពីអនុផលព្រៃឈើនៅក្នុងតំបន់គំរោងគឺ ២៩៥.៥ USD/គ្រួសារ/ឆ្នាំ ស្មើនឹងតំលៃមធ្យមនៃតំលៃដែលទទួលបានក្នុងខេត្តមណ្ឌលគិរី (១៦៧ USD/គ្រួសារ/ឆ្នាំ) និងក្នុងខេត្តក្រចេះ (៤២៤ USD/គ្រួសារ/ឆ្នាំ) ដោយសារខេត្តទាំងពីរមានព្រំប្រទល់ជាមួយតំបន់គំរោង ហើយព្រៃឈើមានលក្ខណៈស្រដៀងគ្នា។

តំលៃសរុបនៃជីវភាពប្រចាំឆ្នាំដែលទទួលបានពីអនុផលព្រៃឈើនៅក្នុងតំបន់គំរោងនឹងស្មើទៅនឹងចំនួនសរុបរបស់គ្រួសារនៅក្នុងតំបន់គំរោង ១៦៧៧ គ្រួសារ គុណជាមួយ ២៩៥,៥ USD/គ្រួសារ/ឆ្នាំ = **៤៩៤.៧១៥** USD/ឆ្នាំ។

## ៩.៥ ធនធានធម្មជាតិនៅក្នុងតំលៃបរិស្ថាន

ដោយសារតំបន់អាងស្តុកដែលមាន FSL ៧៥ម (ធៀបនីវ៉ូទឹកសមុទ្រ) និងតំបន់តាំងទីលំនៅសារជាថ្មីដែលបានស្នើឡើងសំរាប់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី២ ព្រៃឈើនៅក្នុងតំបន់គំរោងនឹងត្រូវខូចខាត ឬបាត់បង់ ដូចដែលមានរៀបរាប់ដូចតទៅ:



Draft

| **ប្រភេទព្រៃឈើ** | **នៅក្នុងតំបន់អាងជាមួយ FSL ៧៥ម** | **ក្នុងតំបន់តាំងទីលំនៅ** | **តំបន់ប៉ះពាល់សរុប** |
|---|---|---|---|
| | (ហ.ត) | (ហ.ត) | (ហ.ត) |
| មិនមែនជាព្រៃ | ៥៨៣១,៤៦១ | ៥៨០,៤០៤ | ៦.៤១១,៨៧ |
| Woodland Evergreen | ៤២,០៧០ | ២២៦,៦៥១ | ២៦៨,៧២ |
| Woodland Deciduous | ៨៣២,៦២៩ | ១,៤៩៩ | ៨៣៤,១៣ |
| ព្រៃស្លួតរដូវប្រាំង | ២៣.០៩៣,០២៧ | ៤.៦១៨.៦៧៧ | ២៧.៧១១,៧០ |
| ព្រៃពាក់កណ្តាលស្រោង | ៣.៥១៦,៥៤៥ | ១.៥៥៦,៩១៩ | ៥.០៧៣,៤៦ |
| ព្រៃស្រោង | ២៤៨,១៩២ | ១០២,៦៥២ | ៣៥០,៨៤ |
| **សរុប** | **៣៣.៥៦៣,៩២៤** | **៧.០៨៦,៨០២** | **៤០.៦៥០,៧៣** |

ប្រើប្រាស់លទ្ធផលពីការសិក្សាស្រាវជ្រាវពី " ផលប្រយោជន៍ពីព្រៃឈើធម្មជាតិនិងការវិភាគសេដ្ឋកិច្ចនៃការអភិរក្សព្រៃឈើធម្មជាតិនៅក្នុងប្រទេសកម្ពុជា = Natural Forest Benefit and Economic Analysis of Natural Forest Conservation in Cambodia" បោះពុម្ពផ្សាយដោយ CDRI ខែ ធ្នូ ឆ្នាំ ២០០៦ សំរាប់តំលៃនៃការគ្រប់គ្រងព្រៃធម្មជាតិដោយនិរន្តរភាព នៅអត្រាបញ្ចុះតំលៃ ១០% មានដូចខាងក្រោម:

- ១១២ USD/ហ.ត/ឆ្នាំ សំរាប់ព្រៃស្លួតរដូវប្រាំង
- ២៤៧ USD/ហ.ត/ឆ្នាំ សំរាប់ព្រៃពាក់កណ្តាលស្រោង
- ៣៧៥ USD/ហ.ត/ឆ្នាំ សំរាប់ព្រៃស្រោង

ផ្ទៃដីព្រៃនឹងត្រូវខូចខាតនៅក្នុងតំបន់អាង

| **ប្រភេទព្រៃឈើ** | **នៅក្នុងតំបន់អាង** (ហ.ត) | គ្របដណ្តប់ដោយព្រៃនិងដីសម្បទាន ៣០%, (ហ.ត) | តំបន់ប៉ះពាល់សរុប (ហ.ត) | តំលៃប្រចាំឆ្នាំជា (USD) | សរុបជា (USD) |
|---|---|---|---|---|---|
| ព្រៃស្លួតរដូវប្រាំង | ២៣.០៩៣,០២៧ | ៦៩២៧,៩០៨១ | ១៦.១៦៥,១២ | ១១២ | ១.៨១០.៤៩៣ |
| ព្រៃពាក់កណ្តាលស្រោង | ៣.៥១៦,៥៤៥ | ១០៥៤,៩៦៣៥ | ២.៤៦១,៥៨ | ២៤៧ | ៦០៨.០១១ |
| ព្រៃស្រោង | ២៤៨,១៩២ | ៧៤,៤៥៧៦ | ១៧៣,៧៣ | ៣៧៥ | ៦៥.១៥០ |
| **សរុប** | **២៦.៨៥៧,៧៦** | **៨.០៥៧,៣៣** | **១៨.៨០០,៤៣** | **៧៣៤** | **២.៤៨៣.៦៥៤** |

Draft

ផ្ទៃដីព្រៃនឹងត្រូវខូចខាតនៅក្នុងតំបន់តាំងទីលំនៅ

| ប្រភេទព្រៃឈើ | នៅក្នុងតំបន់អាង (ហ.ត) | គ្របដណ្ដប់ដោយព្រៃនិងដីសម្បទាន ៦០%, (ហ.ត) | តំបន់ប៉ះពាល់សរុប (ហ.ត) | តំលៃប្រចាំឆ្នាំជា (USD) | សរុបជា (USD) |
|---|---|---|---|---|---|
| ព្រៃស្ងួតរដូវប្រាំង | ៤.៦១៨,៦៨ | ២៧៧១,២១ | ១.៨៤៧,៤៧ | ១១២ | ២០៦.៩១៧ |
| ព្រៃពាក់កណ្ដាលស្រោង | ១.៥៥៦,៩២ | ៩៣៤,១៥ | ៦២២,៧៧ | ២៤៧ | ១៥៣.៨២៤ |
| ព្រៃស្រោង | ១០២,៦៥ | ៦១,៥៩ | ៤១,០៦ | ៣៧៥ | ១៥.៣៩៨ |
| សរុប | **៦.២៧៨,២៥** | **៣.៧៦៦,៩៥** | **២.៥១១,៣០** | **៧៣៤** | **៣៧៦.១៣៨** |

*សង្ខេបពីតំលៃធនធានធម្មជាតិក្នុងមួយឆ្នាំដែលនឹងត្រូវបាត់បង់ដោយគំរោង*

| ល.រ | ពណ៌នា | ការបាត់បង់ប្រចាំឆ្នាំ ជា USD |
|---|---|---|
| ១ | ផលត្រីធម្មជាតិ | ១.២៤៧.៩៧៥,០០ |
| ២ | អនុផលព្រៃឈើ | ៤៩៤.៧១៥,០០ |
| ៣ | និន្នរភាពផលព្រៃឈើធម្មជាតិនៅតំបន់អាង | ២.៤៨៣.៦៥៤,០០ |
| ៤ | និន្នរភាពផលព្រៃឈើធម្មជាតិនៅតំបន់តាំងទីលំនៅសារជាថ្មី | ៣៧៦.១៣៨,០០ |
| | សរុប : | **៤.៦០២.៤៨២,០០** |

Draft

តំលៃព្រៃឈើបាត់បង់នៅក្នុងអាងត្រូវបានកំណត់នៅខាងក្រោមៈ

| ផ្ទៃដីអាង (ជាមួយនីវ៉ូទឹក ៧៥ម) | | | | ការគណនាជីវម៉ាស់ | | | ប៉ាន់ប្រមាណតំលៃ | |
|---|---|---|---|---|---|---|---|---|
| ប្រភេទព្រៃឈើ | ផ្ទៃដី (ហ.ត) | ៣០% នៃដី/សម្បទានព្រៃឈើ (ហត) | ព្រៃឈើបាត់បង់នៅក្នុងតំបន់អាង (ហ.ត) | ជីវម៉ាស់ផ្ទៃខាងលើ សំរាប់ព្រៃឈើខុសគ្នានៃត្រូពិក (Ton/DM/ha)* | ជីវម៉ាស់សរុប (MD),ton | សមមូលជា ១តោននៃ DM=1m³ ព្រៃឈើ | តំលៃនៃព្រៃឈើ (**) USD/m³ | ចំនួន USD |
| Woodland Evergreen | ៤២,០៧០ | ១២,៦២ | ២៩,៤៥ | ៧០ | ២,០៦១,៤៣ | ២,០៦១ | ៤៣ | ៨៨,៦៤១ |
| Woodland Deciduous | ៨៣២,៦២៩ | ២៤៩,៧៩ | ៥៨២,៨៤ | ៨៥ | ៤៩.៥៤១,៤៣ | ៤៩.៥៤១ | ៤៣ | ២,១៣០,២៨១ |
| Deciduous Forest | ២៣,០៩៣,០២៧ | ៦,៩២៧,៩១ | ១៦,១៦៥,១២ | ១២០ | ១,៩៣៩,៨១៤,២៧ | ១,៩៣៩,៨១៤ | ៤៣ | ៨៣,៤១២,០១៤ |
| Semi Evergreen Forest | ៣.៥១៦,៥៤៥ | ១.០៥៤,៩៦ | ២.៤៦១,៥៨ | ២០០ | ៤៩២.៣១៦,៣០ | ៤៩២,៣១៦ | ៥៤ | ២៦.៥៨៥,០៨០ |
| Evergreen Forest | ២៤៨,១៩២ | ៧៤,៤៦ | ១៧៣,៧៣ | ៣០០ | ៥២.១២០,៣២ | ៥២,១២០ | ៨១ | ៤.២២១,៧៤៦ |
| Total | **២៧.៧៣២.៤៦៣** | ៨.៣១៩,៧៤ | ១៩.៤១២,៧២ | | **២.៥៣៥.៨៥៣,៧៤** | | | **១១៦.៤៣៧.៧៦២** |

តំលៃព្រៃឈើបាត់បង់នៅតំបន់តាំងទីលំនៅសារជាថ្មីត្រូវបានកំណត់នៅខាងក្រោមះ

| តំបន់ទីតាំង | | | | ការគណនាជីវម៉ាស់ | | | ប៉ាន់ប្រមាណតំលៃ | |
|---|---|---|---|---|---|---|---|---|
| ប្រភេទព្រៃឈើ | ផ្ទៃដី (ហ.ត) | ៣០% នៃដី/សម្បទានព្រៃឈើ (ហត) | ព្រៃឈើបាត់បង់នៅក្នុងតំបន់អាង (ហ.ត) | ជីវម៉ាស់ផ្នែកខាងលើ សំរាប់ព្រៃឈើ ឧស្សាហ៍នៅត្រូពិក (Ton/DM/ha)* | ជីវម៉ាស់សរុប (MD),ton | សមតុល្យ ១តោននៃ DM=1m³ ព្រៃឈើ | ខ្នាតតំលៃនៃព្រៃឈើ (**) USD/m³ | ចំនួន USD |
| Woodland Evergreen | ២២៦,៦៥១ | ១១៣,៣៣ | ១១៣,៣៣ | ៨៥ | ៩.៦៣២.៦៧ | ៩.៦៣៣ | ៤៣ | ៤១៤.២០៥ |
| Woodland Deciduous | ១.៤៩៩ | ០,៧៥ | ០,៧៥ | ៧០ | ៥២.៤៧ | ៥២ | ៤៣ | ២.២៥៦ |
| Deciduous Forest | ៤.៦១៨,៦៧៧ | ២.៣០៩,៣៤ | ២.៣០៩,៣៤ | ១២០ | ២៧៧.១២០,៦២ | ២៧៧,១២១ | ៤៣ | ១១.៩១៦,១៨៧ |
| Semi Evergreen Forest | ១.៥៥៦,៩១៩ | ៧៧៨,៤៦ | ៧៧៨,៤៦ | ២០០ | ១៥៥.៦៩១,៩០ | ១៥៥,៦៩២ | ៥៤ | ៨.៤០៧,៣៦៣ |
| Evergreen Forest | ១០២.៦៥២ | ៥១.៣៣ | ៥១.៣៣ | ៣០០ | ១៥.៣៩៧,៨០ | ១៥,៣៩៨ | ៨១ | ១.២៤៧,២២២ |
| **Total** | **៦.៥០៦.៣៩៨** | ៣.២៥៣,២០ | ៣.២៥៣,២០ | | **៤៥៧.៨៩៥.៤៥** | | | **២១.៩៨៧.២៣២** |

* ប្រភព: គោលការណ៍ណែនាំ IPCC សំរាប់បញ្ជីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ១៩៩៦

** តំលៃព្រៃឈើសំរាប់ប្រភេទមួយៗ: ព្រៃឈើថ្នាក់ប្រណិត ១៥១-២៨៣ $/m³; ឈើថ្នាក់ I ៨១$/m³; ព្រៃឈើថ្នាក់ II ៥៤$/m³; ឈើថ្នាក់ III ៤៣$/m³; ព្រៃឈើដទៃទៀត I ៤៣$/m³

Draft

សង្ខេបពីការប៉ាន់ប្រមាណតំលៃសំរាប់ការបាត់បង់ព្រៃឈើដោយសារគំរោង

| *ការពិពណ៌នា* | *ផ្ទៃដីបាត់បង់, ហិកតា* | *ជីវម៉ាស់សរុប (DM), តោន* | *តំលៃប៉ាន់ប្រមាណ, USD* |
|---|---|---|---|
| *ការបាត់បង់ព្រៃឈើនៅ ក្នុងអាង* | *១៩.៤១២,៧២* | *២.៥៣៥.៨៥៣,៧៤* | *១១៦.៤៣៧.៧៦២,០០* |
| *ការបាត់បង់ព្រៃឈើនៅ ទីតាំងសង់លំនៅសារជាថ្មី* | *៣.២៥៣,២០* | *៤៥៧.៨៩៥,៤៥* | *២១.៩៨៧.២៣២,០០* |
| ***សរុប*** | ***២២.៦៦៥,៩២*** | ***២.៩៩៣.៧៤៩,២០*** | ***១៣៨.៤២៤.៩៩៤,០០*** |

តាមរយៈការវិភាគនៃជំរើសហិរញ្ញវត្ថុដែលបានស្នើឡើង បានបង្ហាញថា ទីផ្សារបច្ចុប្បន្នមាននិន្នាការផ្លាស់ប្តូរ (អត្រាការប្រាក់របស់ធនាគារ គឺត្រូវបានថយចុះ), នៅពេលដែលការចរចារការទិញ និងការលក់អគ្គិសនី រវាងកម្ពុជា និង វៀតណាមនៅមិនទាន់ដាច់ស្រេច, កិច្ចសន្យាខ្ចីប្រាក់ជាមួយធនាគារ គឺនៅមិនអាចរកបាននៅឡើយ, ហើយការសិក្សាបានបង្ហាញពីសុចនាករហិរញ្ញវត្ថុដូចខាងក្រោមៈ

- ដើមទុនវិនិយោគសរុបៈ ៨១៦.២៣ លានដុល្លាអាមេរិក
- អត្រាការប្រាក់ពីប្រាក់កម្ចីបរទេសៈ ៦%/ឆ្នាំ
- អត្រាការប្រាក់ពីធនាគារពាណិជ្ជក្នុងស្រុកៈ ១៣%/ឆ្នាំ
- រំពឹងពន្ធលើប្រាក់ចំណេញពីកម្ពុជាៈ រយៈពេលអតិបរមា គឺ ៩ឆ្នាំ
- បញ្ចុះតំលៃៈ ១០%

## ការវិភាគហិរញ្ញវត្ថុ និងសេដ្ឋកិច្ច សំរាប់ជំរើសផ្សេងៗនៃតំលៃបរិស្ថាន

មានជំរើសនៃតំលៃបរិស្ថានបីដែលលើកយកមកគណនាដូចមានបង្ហាញខាងក្រោម :-

- ជំរើសទី១ៈ តំលៃបរិស្ថានដែលប៉ាន់ស្មានដោយ PECC1
- ជំរើសទី២ៈ តំលៃបរិស្ថានដែលប៉ាន់ស្មានដោយ KCC
- ជំរើសទី៣ៈ តំលៃបរិស្ថានដែលបានអនុវត្តថ្មីៗនេះនៅក្នុងប្រទេសវៀតណាម

| ប៉ារ៉ាម៉ែត្រ | ជំរើសទី១ | ជំរើសទី២ | ជំរើសទី៣ |
|---|---|---|---|
| សមត្ថភាពតំឡើង (MW) | 400.00 | 400.00 | 400.00 |
| សមត្ថភាពនៃទួប៊ីនមួយគ្រឿង (MW) | 104.00 | 104.00 | 104.00 |
| ថាមពលមធ្យមប្រចាំឆ្នាំ (million kWh) | 1953.87 | 1953.87 | 1953.87 |
| ថាមពលបានការ ( million kWh) | 1944.10 | 1944.10 | 1944.10 |
| **ដើមទុនទៅលើការសាងសង់ Capital Structure** | | | |
| ដើមទុនវិនិយោគសរុប (million USD) | 816.235 | 814.464 | 816.235 |
| ដើមទុនវិនិយោគសរុប (ដោយមិនគិត IDC) (million USD) | 676.174 | 674.737 | 676.174 |
| ប្រាក់សមធមិនៃម្ចាស់គំរោង (million USD) | 206.962 | 206.531 | 206.962 |
| កម្ចីប្រាក់បរទេស (million USD) | 169.099 | 169.099 | 169.099 |
| កម្ចីប្រាក់ពីធនាគារពាណិជ្ជកម្ម (million USD) | 300.113 | 299.107 | 300.113 |

Draft

| | | | |
|---|---|---|---|
| អត្រាការប្រាក់ពីប្រាក់កម្ចីបរទេស | 6% | 6% | 6% |
| អត្រាការប្រាក់ពីប្រាក់កម្ចីក្នុងប្រទេសវៀតណាម (លុយដុង) | 13% | 13% | 13% |
| **សូចនាករហិរញ្ញវត្ថុ Financial indicators** | | | |
| តំលៃលក់ (USc/kWh) | 6.3 | 6.4 | 6.25 |
| NPV (million USD) | 64.002 | 65.425 | 62.600 |
| FIRR% | 12.18% | 12.22% | 12.13% |
| B/C | 1.11 | 1.11 | 1.11 |
| ថ្លៃដើម (USc/kWh) | 5.59 | 5.68 | 5.56 |
| រយៈពេលបង់ប្រាក់ត្រឡប់ (ឆ្នាំ) | 17 | 17 | 17 |
| **សូចនាករសេដ្ឋកិច្ច Economic Indicators** | | | |
| NPV (million USD) | 60.749 | 56.011 | 63.210 |
| EIRR% | 13.27 | 11.35 | 11.23 |
| B/C | 1.19 | 1.17 | 1.20 |

យោងតាមការធ្វើវិភាគហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដែលបានបង្ហាញក្នុងតារាងខាងលើ ការសិក្សាលើគំរោងនេះមានលក្ខណៈសេដ្ឋកិច្ចសំរាប់ការវិនិយោគ ។ ម្យ៉ាងវិញទៀត គិតទៅលើរយៈពេលបង់ប្រាក់ត្រឡប់ ១៧ឆ្នាំ និងតំលៃសំរាប់បន្ធូរបន្ថយបរិស្ថានដែលបានលើកឡើងដោយ ក្រុមសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ KCC នោះតំលៃលក់ដុំនៃចរន្តអគ្គិសនីគឺ ៦,៤ USc/kWh ហើយចំពោះតំលៃបន្ធូរបន្ថយបរិស្ថានដែលបានលើកឡើងដោយ PECC1 នោះតំលៃលក់ដុំនៃចរន្តអគ្គិសនីគឺ ៦,៣ USc/kWh ហើយចំណែកតំលៃបន្ធូរបន្ថយបរិស្ថានដែលបានអនុវត្តនៅប្រទេសវៀតណាម នោះតំលៃលក់ដុំនៃចរន្តអគ្គិសនីគឺ ៦,២៥ USc/kWh ។

Draft